

# ការស្ទង់មតិលើការ យល់ឃើញរបស់ អតិថិជន ២០២៣

OIKO CREDIT
investing in people

FIRST FINANCE

# សេចក្ដីផ្ដើម

ហ្វីស ហ្វាយនែន បានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៩ ហើយបានក្លាយជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឯកទេស ក្នុងការផ្ដល់ឥណទាន លំនៅដ្ឋានខ្នាតតូចរយៈពេលវែង ដំបូងគេក្នុងប្រទេសកម្ពុជា ។ យើងខ្ញុំជឿជាក់ថា ការមានផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន គឺសិទ្ធិជាសកល និងជាគន្លឹះសំខាន់មួយក្នុងការចូលរួមកាត់បន្ថយភាពក្រីក្រ ។ ទស្សនៈវិស័យរបស់យើងខ្ញុំ គឺជួយឱ្យក្រុមគ្រួសារនៅក្នុងប្រទេសកម្ពុជាដែលមានចំណូលមធ្យមកម្រិតទាប  បានរស់នៅក្នុងសេចក្ដីថ្លៃថ្នូរ សុវត្ថិភាព សុភមង្គល និងមានស្ថេរភាព តាមរយៈការផ្ដល់លទ្ធភាពឱ្យពួកគាត់មានផ្ទះ ជាកម្មសិទ្ធិផ្ទាល់ខ្លួន ។

ជាមួយបទពិសោធន៍ច្រើនជាង ១០ ឆ្នាំ ក្នុងឯកទេសផ្ដល់កម្ចីលំនៅដ្ឋានខ្នាតតូច ហ្វីស ហ្វាយនែន បានបម្រើសេវាដល់ប្រជាជន ជិត ៧.៥០០ គ្រួសារក្នុងប្រទេសកម្ពុជា ដែលផ្ដល់នូវផលប៉ះពាល់ជាវិជ្ជមានដល់ជីវិតមនុស្សប្រមាណ ៣០.០០០ នាក់ (ផ្អែកលើការគណនាជាមធ្យម សមាជិក ៤ នាក់ក្នុងមួយគ្រួសារ )។ ៨០% នៃអតិថិជនសរុប គឺជាស្ត្រី ។

ចាប់តាំងពី ភាគហ៊ុន ១០០% ត្រូវបានផ្ទេរឲ្យស្ថិតនៅក្រោមការគ្រប់គ្រងដោយម្ចាស់ភាគហ៊ុនក្នុងស្រុកនៅខែ មិថុនា ឆ្នាំ ២០២២ មក ហ្វីស ហ្វាយនែន មានការរីកចម្រើនទ្វេរដងគួរឲ្យកត់សម្គាល់ ត្រឹមរយៈពេលតែមួយឆ្នាំ។ ដែលនេះបានផ្ដល់វិសាលភាពបន្ថែមទៀតដល់ប្រជាជនដែលមានចំណូលទាប និងមធ្យម ដែលភាគច្រើនពិបាកក្នុងប្រើប្រាស់សេវាលំនៅដ្ឋានផ្លូវការ អាចទទួលបានសេវាកម្ចីលំនៅដ្ឋានខ្នាតតូចរយៈពេលវែង ។

ភាពជោគជ័យរបស់ ហ្វីស ហ្វាយនែន មិនបានវាស់វែងទៅលើសមិទ្ធិផលហិរញ្ញវត្ថុ តែម៉្យាងប៉ុណ្ណោះទេ តែបានរួមបញ្ចូលទាំង សមិទ្ធិផលសង្គម ជាពិសេសផលប៉ះពាល់ជាវិជ្ជមានទៅលើ ជីវភាពប្រចាំថ្ងៃរបស់អតិថិជនយើងខ្ញុំ ។

តាមរយៈការត្រួតពិនិត្យជាប្រចាំ រួមជាមួយឧបករណ៍វាយតម្លៃ អាចឲ្យយើងខ្ញុំវាស់វែងពីលទ្ធផលដែលទទួលបានពីសេវាដែលអតិថិជនបានប្រើប្រាស់ ។ ហ្វីស ហ្វាយនែន មានការប្ដេជ្ញាចិត្តខ្ពស់ក្នុងកិច្ចការពារអតិថិជន និងតម្លាភាព ដែលកិច្ចការទាំងនេះបានបញ្ជាក់យ៉ាងច្បាស់តាមរយៈការទទួលស្គាល់កម្រិតខ្ពស់បំផុត ( កម្រិតមាស ) ដែលត្រូវបានវាយតម្លៃដោយស្ថាប័នអន្តរជាតិ M-Cril នៅខែ មីនា ឆ្នាំ ២០២២ ក្នុងនាមជាស្ថាប័នដែលបានអនុវត្តន៍លើគោលការណ៍ការពារអតិថិជនបានល្អបំផុត ។

ជាផ្នែកមួយនៃកិច្ចប្រឹងប្រែងក្នុងការត្រួតពិនិត្យជាប្រចាំទៅលើផលប៉ះពាល់ យើងខ្ញុំសូមធ្វើការបង្ហាញជូនពីលទ្ធផលនៃការស្ទង់មតិអតិថិជន ដែលបានធ្វើឡើងក្នុងខែកក្កដា ឆ្នាំ ២០២៣ លើការយល់ឃើញរបស់អតិថិជនទៅលើស្ថានភាពដែលពួកគាត់បានជួបប្រទះក្នុងរយៈពេល ១២ ខែកន្លងមកនេះ ។ ការស្ទង់មតិត្រូវបានធ្វើឡើងក្រោមការគាំទ្រពីដៃគូរបស់យើង គឺ OikoCredit ទាំងផ្នែកថវិកា និងបច្ចេកទេស ។ ការទទួលស្ដាប់សំលេងរបស់អតិថិជន អាចផ្ដល់ឱ្យយើង  ទទួលបាននូវព័ត៌មានស៊ីជម្រៅពីការយល់ឃើញរបស់ពួកគាត់ ដែលអាចឲ្យ ហ្វីស ហ្វាយនែន ក៏ដូចជា OikoCredit  បានត្រៀមជាស្រេចសម្រាប់កិច្ចខិតខំប្រឹងប្រែងនាពេលខាងមុខ ។ ការស្ទង់មតិត្រូវបាន ស្រង់ពីអតិថិជនចំនួន ៨៣១ នាក់ ពីទីកន្លែងផ្សេងគ្នា ដែលស្ថិតក្នុងរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ កំពត កំពង់ចាម សៀមរាប បន្ទាយមានជ័យ បាត់ដំបង និងតាកែវ ។

របាយការណ៍នេះ នឹងលើកបង្ហាញអំពីការយល់ឃើញរបស់គាត់ ទៅលើបញ្ហាសំខាន់មួយចំនួនទាក់ទងនឹងបម្រែបម្រួលចំណូល ការសន្សំ ការអភិវឌ្ឍអាជីវកម្ម លទ្ធភាពប្រើប្រាស់បរិក្ខាមូលដ្ឋានក្នុងគ្រួសារ និងការសិក្សា ព្រមជាមួយការចូលរៀនបានទៀងទាត់សម្រាប់កូនៗ របស់ពួកគាត់ដែលមានអាយុ ក្រោម ១៥ ឆ្នាំ ។



# តួរលេខសមិទ្ធិផលសង្គម

**៤.៨០០**
អ្នកមានចំណូលទាប និងមធ្យម

**៤៨%**
ទទួលបានអនាម័យ និងទឹកស្អាត

**៧៩%**
ចំណូលតិចជាង ៧០០ដុល្លារ/ខែ

**៦៧%**
មានផ្ទះជាលើកដំបូង

**៨២%**
អតិថិជនជាស្ត្រី

*ទិន្នន័យគិតត្រឹមខែកក្កដា ឆ្នាំ ២០២២*
**ទទួលបានអនាម័យ និងទឹកស្អាត តាមរយៈកម្ចីកែលម្អផ្ទះ*

# លទ្ធផលស្ទង់មតិអតិថិជន

## ១ ផលវិជ្ជមានដែលបានពីការប្រើប្រាស់កម្ចី

**ភាគច្រើននៃអតថិជនបានយល់ឃើញថា កម្ចីពិតជាបាន ផ្តល់នូវផលវិជ្ជមានដលស្ថានភាពរស់នៅប្រចាំថ្ងៃរបស់គាត់**

- ក្នុងចំណោមអតិថិជនដែលបានចូលរួមស្ទង់មតិ ៨៣១ នាក់ មាន ៧០៤ នាក់ (៨៤% នៃចំនួនសរុប) បាន និយាយថា កម្ចីរបស់ ហ្វីស ហ្វាយនែន ពិតជាបាន ផ្តល់ នូវផលប៉ះពាល់ជាវិជ្ជមានដល់ស្ថានភាពរស់នៅ របស់ គាត់ក្នុងកំឡុងពេល ១២ ខែនេះ ។ ដោយភាគ ច្រើនលើក ឡើងថាពួកគាត់មានផ្ទះសមរម្យរស់នៅ ដោយមាន សុវត្ថិភាព និងសុភមង្គល ។
- ១០៥ នាក់ (១៣% នៃចំនួនចូលរួមសរុប) ឆ្លើយថា កម្ចីមិនបានធ្វើឲ្យជីវភាពរបស់គាត់ប្រែប្រួលអ្វីនោះទេ គឺ នៅដដែល ។
- មានតែ ៤នាក់ប៉ុណ្ណោះ (០,៤៨%) បានឆ្លើយថាកម្ចី បានផ្តល់នូវផលប៉ះពាល់អវិជ្ជមានដល់ជីវភាពរស់នៅ របស់គាត់ ។




ផលវិជ្ជមាន
គ្មានការប្រែប្រួល
ផលអវិជ្ជមាន
មិនដឹង

## ២ ការសំណូមពរ

- ចំណោមអ្នកចូលរួម ៨៣១ នាក់ មានអតិថិជន ៥៨០ (៧០% នៃចំនួនសរុប) បានសំណូមបន្ធូរបន្ថយលើការប្រាក់ និងសេវាផ្សេងៗ
- ៣៦៩ នាក់ (៤៤%) សំណូមពរកែសម្រួលលក្ខខណ្ឌផលិតផលឱ្យបានប្រសើរជាងនេះ
- ២៧៩ (៣៤% នៃចំនួនសរុប) ស្នើឱ្យអភិវឌ្ឍផលិតផលបន្ថែមដើម្បីបំពេញតម្រូវការបន្ថែមរបស់អតិថិជន ដោយហេតុថាបច្ចុប្បន្ន ហ្វីស ហ្វាយនែនផ្តោតទៅលើតែកម្ចីលំនៅដ្ឋាន ។




## ៣ បម្រែបម្រួលលើប្រាក់ចំណូល

**ភាគច្រើននៃអ្នកចូលរួម បានយល់ឃើញថាប្រាក់ចំណូលរបស់គាត់មានការកើនឡើងនៅក្នុងរយពេល ១២ខែនេះ ។ (ការវិលត្រឡប់មករកប្រក្រតីភាពវិញ ក្រោយកូវីដ ។**

- ក្នុងចំណោម ៨៣១នាក់ ដែលបានផ្តល់ព័ត៌មានទាក់ទងនឹង បម្រែបម្រួលប្រាក់ចំណូល មាន ៥២២ នាក់ (៦៣%) និយាយថា ចំណូលពួកគាត់បានកើនឡើងក្នុងរយៈពេល ១២ ខែចុងក្រោយ ។
- ២៥១(៣០%) និយាយថាប្រាក់ចំណូលរបស់គាត់មិនមានការប្រែប្រួលទេ ក្នុងរយៈពេល ១២ ខែនេះ ។
- មានតែ ៥៨ នាក់ប៉ុណ្ណោះ (៧% នៃចំនួនសរុប) បានបង្ហាញថាចំណូលពួកគាត់បានធ្លាក់ចុះ ។
- ភាគច្រើនបានពន្យល់ថាការកើនឡើងនៃចំណូល ដោយសារការលក់នៃអាជីវកម្មដែលមានស្រាប់មានការកើនឡើង និងប្រាក់ខែសម្រាប់ការងារដែលកំពុងមានស្រាប់មានការកើនឡើង ។



## ៤ បម្រែបម្រួលលើប្រាក់សន្សំ

**ភាគច្រើននៃអ្នកចូលរួម បានយល់ឃើញថា ប្រាក់សន្សំរបស់គាត់មានការកើនឡើងក្នុងរយៈពេល ១២ខែកន្លងទៅនេះ ។**

- ក្នុងចំណោម ៦៨២ នាក់ដែលបានផ្តល់ចម្លើយទាក់ទងនឹងប្រាក់សន្សំ មាន ៤៦៩ នាក់ (៦៩%) បាននិយាយថា ប្រាក់សន្សំរបស់ពួកគាតបានកើនឡើងក្នុងរយៈពេល ១២ខែចុងក្រោយនេះ ។
- ១៨៧ នាក់ (២៧% នៃចំនួនសរុប) បានលើកឡើងថា ប្រាក់សន្សំមិនមានការប្រែប្រួល  គឺនៅដដែល ។
- មានតែ ២៨ នាក់ (៤%) បានបញ្ជាក់ថា ប្រាក់សន្សំរបស់ពួកគាត់មានការថយចុះ ។




## ៥ ការកែលម្អគេហដ្ឋាន

ក្នុងចំណោមអ្នកចូលរួម ដែលបានប្រើប្រាស់កម្ចីកែលម្អគេហដ្ឋាន មាន ៩០% បាននិយាយថា ពួកគាត់បានជួសជុល ឬកែលម្អគេហដ្ឋានក្នុងរយៈពេល ១២ ខែកន្លងទៅនេះ ។

ក្នុងនោះ ៥៩% បានប្រើប្រាស់កម្ចីដើម្បីកែលម្អទៅលើគ្រឿងបរិក្ខាបន្ទប់ទឹក និងបង្គន់ ។



**៥៩%**

បានកែលម្អទៅលើបរិក្ខាបន្ទប់ទឹក និងបង្គន់



## ៦ បម្រែបម្រួលលទ្ធភាពលើការប្រើប្រាស់បរិក្ខាមូលដ្ឋាន (អគ្គីសនី ការចម្អិនអាហារ ទឹកម៉ាស៊ីន អនាម័យ ...)

- ក្នុងចំណោមអ្នកចូលរួមសរុប ចំនួន ៨៣១ នាក់ ដែលបានផ្តល់ព័ត៌មានទាក់ទងនឹងបម្រែបម្រួលលទ្ធភាព ក្នុងការប្រើប្រាស់បរិក្ខាមូលដ្ឋានក្នុងផ្ទះ មាន ៨១៧ នាក់ ( ៩៨% នៃចំនួនសរុប ) បានឆ្លើយថា លទ្ធភាពប្រើប្រាស់បរិក្ខាមូលដ្ឋានមានការកើនឡើង និង នៅដដែល ក្នុងរយៈពេល ១២ ខែចុងក្រោយនេះ ។
- មានតែ ៧នាក់ប៉ុណ្ណោះ ( 0,៨៥% នៃចំនួនសរុប ) បានលើកឡើងថា លទ្ធភាពក្នុងការប្រើប្រាស់បរិក្ខាមូលដ្ឋាន ដូចជា អគ្គីសនី ការចំអិនអាហារ និងម៉ាស៊ីនត្រជាក់ កង្ហារ មានការធ្លាក់ចុះ ដោយមូលហេតុចំណូលធ្លាក់ចុះ ក្នុងកំឡុងពេល ១២ ខែកន្លងនៅនេះ ។




---

## ៦ មានទូរសព្ទស្មាតហ្វូន និងអ៊ីនធឺណែតប្រើប្រាស់

ក្នុងចំណោមអ្នកចូលរួមសរុប ៨៣១ នាក់ក្នុងការផ្តល់ព័ត៌មានអំពីការប្រើប្រាស់ទូរសព្ទស្មាតហ្វូន និងអ៊ីនធឺណែត មាន ៨០៤ នាក់ ( ៩៧% នៃចំនួនសរុប ) បានឆ្លើយថាពួកគាត់មានទូរសព្ទស្មាតហ្វូនប្រើ ដែលអាចភ្ជាប់ខ្លួន ទៅកាន់បណ្តាញសង្គម តែឡេក្រាម Whatapp ការជួបតាមប្រព័ន្ធអនឡាញ ឬវីដេអូខល ក៏ដូចជាការទទួលបាននូវប្រភពព័ត៌មាន ។



**៩៧%**
មានស្មាតហ្វូនប្រើ និងភ្ជាប់ទៅកាន់អ៊ីនធឺណែត

## ៨ ការសិក្សារបស់កុមារ

**៦២% នៃអ្នកចូលរួមសរុប មានកូនអាយុក្រោម ១៥ ឆ្នាំ ។ ដោយភាគច្រើនបានឆ្លើយថា កូនៗរបស់គាត់បានចូលរៀនទៀងទាត់ ។**

- ក្នុងចំណោមអ្នកចូលរួម ៥១៥ នាក់ ដែលផ្តល់ព័ត៌មានទាក់ទងនឹងការចូលរៀនរបស់កូនៗ មាន ៤៧៨ នាក់ (៩២% នៃចំនួនសរុប) បានលើកឡើងថា កូនៗរបស់គាត់បានចូលរៀនទៀងទាត់ក្នុងរយៈពេល ១២ ខែចុងក្រោយនេះ ។
- ៤០ នាក់ (៨% នៃចំនួនសរុប) បានបញ្ជាក់ថា កូនៗរបស់គាត់ដែលមានអាយុក្រោម ១៥ ឆ្នាំ មិនបានចូលរៀន ។
- ហេតុផលចម្បងដែលមិនបានចូលរៀនពីព្រោះក្មេងៗទាំងនោះមិនទាន់គ្រប់អាយុចូលរៀនតាមសាលាតម្រូវនៅឡើយ ។



**៩២%**

នៃក្មេងដែលមានអាយុក្រោម ១៥ ឆ្នាំ បានចូលរៀនទៀតទាត់នៅសាលា




## ៩ ការយល់ឃើញពីស្ថានភាពអនាគត

**ភាគច្រើននៃអ្នកចូលរួម មិនសូវមានក្តីបារម្ភពីអនាគតខាងមុខ និងខ្លះយល់ឃើញថានឹងមិនមានអ្វីផ្លាស់ប្តូរក្នុងរយៈពេល ខាងមុខ ។**

- ក្នុងចំណោមអ្នកចូលរួម ៨៣១ នាក់ ដែលបានផ្តល់ការយល់ឃើញទៅលើស្ថានភាពអនាគតខាងមុខ មាន ៤៥២ នាក់ (៥៤% នៃចំនួនសរុប) បាននិយាយថា ពួកគាត់មិនសូវបារម្ភពីអនាគតខាងមុននោះទេ ។
- ២៨៩ នាក់ (៣៥% នៃចំនួនសរុប) យល់ឃើញថា នឹងមិនមានអ្វីផ្លាស់ប្តូរនោះទេ នៅពេលខាងមុខ ។
- មានតែ ៧៩ នាក់ប៉ុណ្ណោះ (៩% នៃចំនួនសរុប) បានលើកឡើងពីក្តីបារម្ភខ្លាំងពីអនាគតខាងមុខ។



# ការស្ទង់មតិលើការ
# យល់ឃើញរបស់
# អតិថិជន ២០២៣


## ការិយាល័យកណ្ដាល

អគារលេខ២៩៦ ផ្លូវលេខ២៧១
សង្កាត់ ទួលទំពូង ទី២
ខណ្ឌ ចំការមន រាជធានីភ្នំពេញ

023 997 937
www.firstfinance.com.kh
firstfinance